ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៦២១ អយក.ប្រក

**ប្រកាស**

ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ **សំបូរមាស**

មកជាសាលាបឋមសិក្សាពេញលក្ខណៈ

---

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

-បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

-បានពិនិត្យលិខិតលេខ ១២ អយក.ខដ ចុះថ្ងៃទី ១៣ ខែ ២ ឆ្នាំ ២០០២ របស់ការិយាល័យអប់រំ យុវជន និង កីឡា ខណ្ឌ **ដង្កោ** រាជធានីភ្នំពេញ

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**ស ម្រេ ច**

**ប្រការ១** :- ផ្តាច់សាលាឧបសម្ព័ន្ធ **សំបូរមាស** ពីសាលាបឋមសិក្សា **ដង្កោ** ដែលមានទីតាំងស្ថិតនៅភូមិ **សំបូរ** សង្កាត់ **ដង្កោ** ខណ្ឌ ដង្កោ **រាជធានី ភ្នំពេញ** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :- សាលាបឋមសិក្សា **សំបូរមាស** ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** :- នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤** :- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥** :- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា **រាជធានីភ្នំពេញ** ការិយាល័យអប់រំ យុវជន និង កីឡា ខណ្ឌ **ដង្កោ** នាយកសាលាបឋមសិក្សា **សំបូរមាស** នាយកសាលាបឋមសិក្សា ដង្កោ មានភារកិច្ច អនុវត្តប្រកាសនេះ ។

<u>**កន្លែងទទួល**</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាលាក្រុងភ្នំពេញ

<u>"ដើម្បីជូនជ្រាបជាពត៌មាន"</u>

- ដូចប្រការ ៥
- កាលប្បវត្តិ
- ឯកសារ នា -ប.ម

ភ្នំពេញ .ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០២

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា**

**រដ្ឋលេខាធិការ**

[illegible]